មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0116**

# សម្ភាសន៍ជាមួយឈ្មោះ លឹម វុធឌី ភេទប្រុស អាយុ៦៥ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានឈ្លប

## មុខងារបច្ចុប្បន្នៈ កសិករ

## សព្វថ្ងៃរស់នៅភូមិបន្ទាយឆ្មារខាងជើង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០:៤៣:៥៦

១៤ទំព័រ

ប៊ុនថន ៖ លោកពូឈ្មោះអីដែរ?

វុធឌីៈ ខ្ញុំបាទឈ្មោះ លឹម វុធឌី ។

ប៊ុនថន ៖ ពូអាយុប៉ុន្មានហើយ?

វុធឌីៈ អាយុ៦៥-៦៦ ហើយ ។

ប៊ុនថន ៖ ពូស្រុកកំណើតនៅណាដែរ?

វុធឌីៈ ស្រុកកំណើតកើតនៅបន្ទាយឆ្មារ ពីដើមខ្ញុំកើតនៅខាងសុរិន្ទ បុរីរះនោះ តែចុះមកសម័យពាក់កណ្តាលសាសនា ប្រហែលហាសិបជាងឆ្នាំហើយ ខ្ញុំអាយុបាន៧ឆ្នាំ ។

ប៊ុនថន ៖ ពូកើតនៅសុរិន្ទទេ?

វុធឌីៈ នៅបុរីរះ នៅភូមិទន្លាប ឃុំសង្កែ ស្រុកអំពើសទឹក តែខេត្តបុរីរះ ។

ប៊ុនថន ៖ អំពិលអី?

វុធឌីៈ ឃុំសង្កែ តែភូមិនោះភូមិទន្លាប តែស្រុកនោះអំពើសទឹក ។

ប៊ុនថន ៖ អំពិលសទឹក?

វុធឌីៈ អំពើនេះគឺស្រុក ស្រុកសទឹក ខេត្តបុរីរះ ។

ប៊ុនថន ៖ ពូម្តាយឪពុកនៅនោះទេ?

វុធឌីៈ មកនេះទាំងអស់ ចុះមកនៅ ។

ប៊ុនថន ៖ ចុះមកនៅឆ្នាំប៉ុន្មាន?

វុធឌីៈ ខ្ញុំមិនចាំទេ ។

ប៊ុនថន ៖ តាំងពីពូអាយុ៧ឆ្នាំ?

វុធឌី:		ខ្ញុំអាយុ៧៥ឆ្នាំ ។

ប៊ុនថន :	ម៉េចបានផ្លាស់មក?

វុធឌី:		កាលសម័យនោះស្រុកស្រែវារាំង ធ្វើស្រែមិនកើត ទឹកលិចក៏លិច ។

ប៊ុនថន :	ដោយសារាំង និងទឹកលិច ។ ចុះក្រៅពីគ្រួសារពូមានគ្រួសារផ្សេងមកទេ?

វុធឌី:		មក៨០គ្រួសារ កាលមក គ្រាន់តែរទេះ៨០រទេះ វាដេញទាំងគោ ទាំងរទេះ មកទាំងអស់ ។

ប៊ុនថន :	យើងមកតែម្តង មិនមែនអាជ្ញាធរថៃគេនេះមកទេ?

វុធឌី:		អត់ទេ កាលសម័យនោះគឺអ្នកណាទៅណាក៏បាន ពាក់កណ្តាលសាសនា មុនពាក់កណ្តាលសាសនា ។

ប៊ុនថន :	លោកពូមកនៅនេះតាមរយៈបងប្អូនទេ មកនៅបន្ទាយឆ្មារ?

វុធឌី:		ខ្ញុំមកនៅបន្ទាយឆ្មារនេះកាលឆ្នាំ៩១ មុនគេជម្លៀសចេញពីសាយធូមក កាលពី៧៥នេះខ្ញុំរត់ទៅនៅថៃ នៅថៃរួចមកនៅតស៊ូនឹងជាយដែនអស់រយៈពេលយូរហើយ មើល៧៨ខ្ញុំឈប់ពីធ្វើការផ្សារពីប៉ាវ៉ា ៧៨ខ្ញុំបាទឈប់ ។

ប៊ុនថន :	លោកពូមកពីថៃដំបូង ពូនៅណា? ចេញមក?

វុធឌី:		ចេញមកនៅភូមិក្បាលទន្សោង ។

ប៊ុនថន :	ឃុំបន្ទាយឆ្មារ?

វុធឌី:		ឃុំបន្ទាយឆ្មារ ។

ប៊ុនថន :	មកដល់ពូធ្វើអីវិញ? មកដល់ដំបូង?

វុធឌី:		ទេ មកដល់ ។

ប៊ុនថន :	ធ្វើស្រែចម្ការ?

វុធឌី:		ធ្វើស្រែចម្ការ គ្មានធ្វើអីក្រៅពីស្រែចម្ការទេ ។

ប៊ុនថន :	ចុះឪពុកម្តាយលោកពូរកស៊ីអីដែរ?

វុធឌី:		ម្តាយឪពុកគាត់ធ្វើស្រែចម្ការ ចិញ្ចឹមគោ គោសម័យហ្នឹងមានគោមេ៣៨០ក្បាល ក្របី ៨០ក្បាល ។

ប៊ុនថន :	ច្រើនដែរពូ?

វុធឌី:		ដល់មកសម័យប៉ុលពតនេះ គេដាក់រួមបាត់ ដាក់ចូលរួមទាំងគោ ទាំងក្របី មិនថាតែទ្រព្យសម្បត្តិអីទេ ដាក់រួមទាំងអស់ ។

ប៊ុនថន ៖ ពូមកដល់ដំបូងមានបានចូលរៀនសូត្រអីទេ?

វុធឌី៖ ខ្ញុំកាលមកពីថៃ ខ្ញុំមករៀននៅបន្ទាយឆ្មារយើង រៀនសាលា កាលនោះមិនទាន់មាន សាលា ត្រឹមត្រូវទេ មានតែវត្ត នៅនឹងវត្ត រៀននឹងវត្ត រៀនទៅបានថ្នាក់ទី៩ក៏ឈប់មិន បានរៀន

តទៅទៀត ។

ប៊ុនថន ៖ ម៉េចបានឈប់ពូ?

វុធឌី៖ កាលសម័យនោះ ផ្លូវកណ្តាលទៅរៀនកាលនោះ ដើរដល់ស្វាយ មិនមែនផ្លូវថ្នល់អីទេ ពីដើមគ្នាទៅថ្មពួក បរទេះសឹងតែបរមិនកើត ។

ប៊ុនថន ៖ អីចឹងទៅរៀន រៀននៅ?

វុធឌី៖ រៀននៅវត្តនឹងបន្ទាយឆ្មារ ។

ប៊ុនថន ៖ អីចឹងដោយសារនោះឆ្ងាយពូមិនបន្តទៅ?

វុធឌី៖ បាទ! នោះឆ្ងាយមិនបានទៅរៀនត ។

ប៊ុនថន ៖ ចុះបងប្អូន បានទៅរៀន?

វុធឌី៖ បងប្អូន១២នាក់ តែខូចអស់ក្រែលហើយ នៅសល់ប៉ុន្មាន ៦នាក់នៅសល់ ។

ប៊ុនថន ៖ តែកូនទីប៉ុន្មានពូ?

វុធឌី៖ ខ្ញុំកូនទី២ ។

ប៊ុនថន ៖ កូនទី២ ?

វុធឌី៖ ទី១២នោះ ។

ប៊ុនថន ៖ កូនទី១២ ?

វុធឌី៖ ទី១១ មីប្អូនខ្ញុំទី១២ កូន១២នាក់ ក្នុងមួយក្រុមគ្រួសារខ្ញុំ ។

ប៊ុនថន ៖ ក្រោយពីឈប់រៀនពូទៅណាទៀតពូ?

វុធឌី៖ កាលសម័យនោះនៅធ្វើទាហាន មិនទាន់ទាហាន លន់ នល់ ដល់ធ្វើទាហានទៅ សម័យ ប៉ុលពត មក នៅធ្វើទាហាន ដល់សម័យ៧៩ក៏ខ្ញុំរត់ ព្រះអង្គម្ចាស់ចន្ទ័រង្សី គាត់កាន់មេទ័ព គាត់សក្តិ៥នាំគាត់រត់ចេញ តាឈៀងវេង ក៏សក្តិ៥ដែរនៅនេះ តានងហ៊ាន លោកនាម គាត់នៅនេះដែរ កាលមុនដំបូងខ្ញុំនៅខាងទាហាន ខ្ញុំនៅខាង ឡឹក សំអឿន គេហៅ ផ្កាយព្រឹក នោះសម័យនោះ ។

ប៊ុនថន ៖ ខាង លន់ នល់?

វុធឌីៈ ទេ កាលនោះនៅមិនទាន់ច្បាស់ថាខាង លន់ នល់ មែនទែនទេ វានៅកាន់ទិស ។

ប៊ុនថន ៈ ខាងសេរី ឬខាង?

វុធឌីៈ វាចូលខ្មែរសេរីពួកនេះ នៅបង្ករកើតជាខ្មែរសេរី បង្កើតបានប្រហែលប៉ុន្មានទៅក៏ម៉ត់ គេហៅថាម៉ត់ លោក សឺងតូ លោកទៅអូសទាញមកទាំង ឡឹក សំអឿន មកខាងយើង ។

ប៊ុនថន ៈ ចូលមកខាង?

វុធឌីៈ ខាង លន់ នល់ ។

ប៊ុនថន ៈ កាលហ្នឹងពីណាមេគេ?

វុធឌីៈ កាលនោះមានអ្នកណា ឡឹក សំអឿន, ប៉ុនសន, លោក ឡាំសិនមិន សក្តិ១, លោក ដៃ សក្តិ២, លោក ឈួង សក្តិ៣ ។

ប៊ុនថន ៈ ពូចូលហ្នឹងច្រើនទេកំលាំង?

វុធឌីៈ កំលាំងច្រើន ខ្ញុំនៅស្មាច់ ខ្ញុំទាហានស៊ាប់ហើយ ខ្មោចគារិច, អាលឿន, អាឡូ ស៊ាប់ម៉ត់ អស់ហើយ ស៊ាប់ច្រើន ។

ប៊ុនថន ៈ ប្រហែលជាកំលាំងទាំងអស់ប៉ុន្មានពូ ខាងខ្មែរសេរី?

វុធឌីៈ ច្រើន នៅប៉ែកខាងនេះចំនួន នៅខាងស្មាច់មិនទដល់១០០០នាក់ទេ មួយវរៈសេនាតូច ។

ប៊ុនថន ៈ កាលហ្នឹងកើតឆ្នាំណាខ្មែរសេរីហ្នឹង តាមពូនៅក្នុងហ្នឹង?

វុធឌីៈ ខ្ញុំចាំមិនបាន មើលមុនខ្មែរក្រហម ។

ប៊ុនថន ៈ មុនរដ្ឋប្រហារទៀតពូ?

វុធឌីៈ មុនរដ្ឋប្រហារឆ្ងាយគ្រាន់ ប្រហែល៣ឆ្នាំ ។

ប៊ុនថន ៈ អំឡុងឆ្នាំ៦៧-៦៨ អីហ្នឹងពូ?

វុធឌីៈ បាទ!

ប៊ុនថន ៈ ដំបូងម៉េចបានពូដឹងថាចូលទៅជាមួយខ្មែរសេរី?

វុធឌីៈ គេមកនាំ អាស៊ាយ នេះវាទៅអាមេរិកហើយ កាលសម័យនោះ មានអ្នកណាគេអ្នកនាំ មានពួក តានង៉ហ៊ាន, អាចារ្យស្គន់ គេអាស្គង់, បង ផន់ នៅតាមគោកព្រិច ។

ប៊ុនថន ៈ ដំបូងបង្កើតដើម្បីអីវិញពូខ្មែរសេរីហ្នឹង?

វុធឌីៈ ទេខ្ញុំក៏មិនច្បាស់អំពីគោលការណ៍គេ ប្រហែលជាគេនឹងទាញទៅខាងខ្មែរក្រហមពួកហ្នឹង មិនបានរៀនសូត្រអីទេ ទៅគេថារើស។ទៅ ។

ប៊ុនថន ៈ ពូចូលទៅអត់ថាធ្វើអីទេ ដើម្បីអីទេ?

វុធឌី:　　មិនដឹង ។

ប៊ុនថន :　　ចេះតែចូលតាមគេទេ?

វុធឌី:　　ចេះតែធ្វើតាមគេ អានេះមកហៅចេះតែទៅ ។

ប៊ុនថន :　　ចុះចូលជាមួយខាង លន់ នល់ ឆ្នាំប៉ុន្មាន? ពេលរដ្ឋប្រហារហើយ?

វុធឌី:　　ដល់មក លន់ នល់ ហើយប្រហែលឆ្នាំ៦៦-៦៧ ។ កាលនោះអានេះហើយវ៉ៃពួកខ្ញុំទៅ ជួយវ៉ៃខ្មែរក្រហម ឲ្យទៅខាងខ្មែរក្រហម ទៅនៅខាងស្អាង ។

ប៊ុនថន :　　កាលហ្នឹងចុះចូលជាមួយខាង លន់ នល់?

វុធឌី:　　បាទ! កាលនោះលោកទៅដឹកនាំមក លោក សឹងតូ ទៅអូសទាញចេញពីនោះ ។

ប៊ុនថន :　　ពីណា? ឈ្មោះអីវិញ?

វុធឌី:　　លោក សឹងតូ ងាប់ហើយ ងាប់កាលសម័យប៉ុលពត ។

ប៊ុនថន :　　អូសទាញចេញពី?

វុធឌី:　　ពីដើមម៉ិញគេនៅកន្លែងធំនៅកន្លែងភ្នំវ៉ៃចាប ។

ប៊ុនថន :　　ពូថានាំព្រះអង្គម្ចាស់ ចន្ទ័រង្សី ទៅណាពេលហ្នឹង?

វុធឌី:　　កាលហ្នឹងរត់សម័យខ្មែរក្រហម គាត់មិនចុះចូលនឹងខ្មែរក្រហម គាត់ឲ្យជូនចេញទៅឡាន៥ អាវុធ គ្រាន់តែចេញទៅគេប្រគល់ឲ្យថៃអស់ គាត់បួសដល់សព្វថ្ងៃ បួសនៅសុរិន្ទ ហៅវត្តភ្នំដែក ។ សំដីអ្នកជិតខាង“ សឹកហើយ” ។ សឹកឯណា លោកមានសឹក លោកដើរ តែប្រទេសក្រៅ ។

ប៊ុនថន :　　ចូលមកខាងជាមួយ លន់ នល់ ឆ្នាំប៉ុន្មានពូ? ចូលមកវិញកំលាំងហ្នឹង? ចុះចូល?

វុធឌី:　　កំលាំងកាលហ្នឹងចុះចូលមកខាង លន់ នល់ ខ្ញុំចាំមិនបាន ៦៧-៦៨ ។

ប៊ុនថន :　　ចុះចូលហើយពូមកខាងទ័ព លន់ នល់ វិញ?

វុធឌី:　　បាទ!

ប៊ុនថន :　　ពូកាលហ្នឹងឈរជើងនៅណាវិញ? នៅខាងភ្នំពេញ ឬមួយនៅ?

វុធឌី:　　ខ្ញុំគេផ្លាស់ ពីដើមម៉ិញនៅស្ទាច់ ចេញពីស្ទាច់មកនៅភ្នំទ្រព្យ កៀកភ្នំស្រុក នៅពោធិ៍ចិនតុង នៅភ្នំពេញយើងតារាងកប៉ាល់ហោះក៏នៅ ទៅនៅស្អាងនោះក៏នៅ នៅមន្ទីរព្រែកប៉ាស់នេះ ក៏នៅ នៅច្រើនកន្លែងណាស់ទាហាន ចេះតែផ្លាស់ប្តូរ ។

ប៊ុនថន :　　កាលហ្នឹងពូនៅជាប់ជាមួយអ្នកណា? មេ?

វុធឌី:　　កាលហ្នឹងព្រះអង្គម្ចាស់ ច័ន្ទរង្សី លោកជាមេ ហៅ ម៉ង់តង់ដប់ពីរ ។

ប៊ុនថន ៖ គាត់ខ្សែខាងស្ដេច?

វុធឌី៖ ខ្ញុំលឺតែគេថាព្រះអង្គម្ចាស់ ហៅតាមគេ ។

ប៊ុនថន ៖ ដឹងប្រវត្តិគាត់?

វុធឌី៖ មិនដឹងប្រវត្តិគាត់ថាកូនចៅអ្នកណា មិនច្បាស់រឿងកូនចៅ ។

ប៊ុនថន ៖ ពេលបែកភ្នំពេញភ្ជាមពូនៅណា? កាលបែកដំបូង?

វុធឌី៖ កាលបែកខ្ញុំរត់ គេចាប់ប៉ុលពតចាប់ខ្ញុំទៅបើកលុយនៅសៀមរាប គេចាប់នឹងវាលចន្ទ្រា គេចាប់ទៅទុកធិបតីក្ដាន់រុន គេចាប់យកទៅនៅនោះ ខ្ញុំបានអ្នក ឡុងវង់ ស្រុកស្រែងស្ពាន នាំគ្នារត់ ជិះម៉ូតូទៅ ខ្ញុំមិនដឹង ស្មានតែពួកគេហៅថាពួកក្អែកទឹក ពួកស្លៀកខ្មៅពាក់ខ្មៅ ដល់នេះទៅក៏គេឡើងមកកាត់ស្ពាន ក៏គេស្នើរមួយរយៈខ្ញុំ មិនមែនគ្នាយើងទេ ខុសខ្លួនទាំងអស់ កាលហ្នឹងបើខ្ញុំមិនដោះលេខម៉ូតូ ជិះបំបុកប្រហែលគេបាញ់ ។

ប៊ុនថន ៖ អីចឹងពួយាត់ពូអត់ឈប់ទេ?

វុធឌី៖ ឈប់ ខ្ញុំក៏ដោះលេខម៉ូតូមកក៏ឈប់ ឈប់គេនាំចុះ ចុះទៅនៅជិតក្ដាន់រុនដីក្បែរសៀមរាប ទៅដីដែលគេរំដោះបាន កាលនោះគេមិនទាន់វៃបានគេ ។

ប៊ុនថន ៖ ប៉ុន្តែពូពាក់ឯកសណ្ឋានទេកាលហ្នឹង?

វុធឌី៖ ខ្ញុំស្លៀកពាក់ប៉ារ៉ាធម្មតា ស្លៀកពាក់ទាហាន ។

ប៊ុនថន ៖ ឯកសណ្ឋានទាហាន?

វុធឌី៖ បាទ! ទៅបើកលុយបើកកាក់ លុយកាក់កាលហ្នឹងគេយកប៉ុន្មាន ។

ប៊ុនថន ៖ ហើយពូធ្វើម៉េចបានរួចពីហ្នឹងមក?

វុធឌី៖ ខ្ញុំទៅនៅជាមួយគេ៣ខែ គេក៏ឲ្យមកស៊ើបការណ៍វៃភ្នំស្រុក ខ្ញុំ និង ឡូមវឿង ស័គ្រចិត្តថាមកឈ្លបយកការណ៍ឲ្យគេទៅចុះ ដល់ហើយនាំគ្នារត់ មកដល់នេះចូលក្នុងបន្ទាយមកប្រាប់លោក សឹងតូ ចាំមើលតែសម្ដេចចូលមកហើយនិង អាចារ្យទុំ ចូលមកគាត់អត់មានបញ្ហាទេ ពីព្រោះគាត់ធ្វើស្មៀនសម្ដេចតាំងពីដើម តាំងពីឥស្សរៈ ។

ប៊ុនថន ៖ ឈ្មោះអីវិញ?

វុធឌី៖ លោក សឹងតូ សក្តិ៥ កាលសម័យនោះ ។ លោក សឹងតូ នេះលោកពីដើមម៉ិញត្រូវជាបងថ្លៃខ្ញុំ ។

ប៊ុនថន ៖ ចុះឈ្មោះគាត់ពេញឈ្មោះអីវិញពូ?

វុធឌី៖ ហៅតែលោក សឹងតូ អីចេះឯង ។

ប៊ុនថន : អីចឹងពូមកភ្នំស្រុក មកហ្នឹងរត់ចូលមកបន្ទាយខាងនេះវិញ?

វុធឌី: ព្រោះដែលមក មកប្រាប់គាត់ គេឲ្យមកវៃ ឲ្យមកយកការណ៍ មកវៃបន្ទាយភ្នំស្រុក ខ្ញុំចូលមកដល់ខ្ញុំប្រាប់គាត់ ឲ្យគាត់ជូនមកផ្ទះ ទៅឡើង៣ខែនោះ អ្នកផ្ទះថាខ្ញុំងាប់អស់ ចប់ទៅ ។ មកប្រាប់លោក សឹងតូ គាត់ថាអញទៅភ័យអី តែ អាចារ្យទុំ សម្ដេចគាត់ចូលមកអញធ្វើស្មៀនគាត់ពីយូរណាស់ហើយ តាំងពីសម័យឥស្សរៈ ធ្វើស្មៀន ជាមួយខ្មោចអាចារ្យទុំ ។

ប៊ុនថន : អីចឹងពូរត់មកផ្ទះហ្នឹងមកនៅណា?

វុធឌី: នៅក្បាលទន្សោង ។

ប៊ុនថន : ពូនៅហ្នឹងរហូតដល់?

វុធឌី: ដល់៧៩ ចុង៧៩នេះគេក៏រើសខ្ញុំឲ្យធ្វើឈ្លប ធ្វើប្រធានឈ្លបនាំគ្នាទៅ គេឲ្យទៅបិទប្រឡាយជីកប្រឡាយ តាមបឹង តាមថ្នល់ដាច់ បិទប្រព័ន្ធភ្លឺ ធ្វើភ្លឺក្រឡាឈើត្រង់យើងពួកខ្ញុំយុវជន យុវនារី ទៅបិទ ។

ប៊ុនថន : ពូថាជួយព្រះអង្គម្ចាស់ ច័ន្ទរង្សី ហ្នឹងទៅឆ្នាំប៉ុន្មាន?

វុធឌី: ៧៩ហ្នឹងឯង ខ្ញុំជូនទៅរួចខ្ញុំត្រឡប់មកវិញ ។

ប៊ុនថន : កាលហ្នឹងពូធ្វើប្រធានឈ្លបនៅ?

វុធឌី: ទេ ខ្ញុំទើបតែ...ទេ ខ្ញុំត្រឡប់មកវិញ មកនៅពាក់កណ្ដាលឆ្នាំគេចូលមករៀបចំរួចហើយ ។

ប៊ុនថន : ពូជូនគាត់ហ្នឹង ក្រៅពីគាត់ច្រើនទេ?

វុធឌី: ខ្ញុំជូនទៅ មើលទៅឡាន៥ មនុស្សច្រើនក្រៃល ។

ប៊ុនថន : តាមច្រកណាដែរ?

វុធឌី: ទៅផ្លូវសម្បូរឆ្ងាញ់ ពីដើមម៉ិញ ។

ប៊ុនថន : អត់អីដែលពូខាងថៃគេ?

វុធឌី: ខាងថៃគេទទួល ដល់នេះគេដកអាវុធម៉ត់ ។

ប៊ុនថន : ឲ្យតែមនុស្សចូលទេ?

វុធឌី: បាទ!

ប៊ុនថន : ពូចេះភាសាថៃទេ?

វុធឌី: កាលនោះចេះហើយ ដូចថាទៅមកៗ ក្បាលទន្សោងទៅថៃនេះ ទៅមកៗ រកស៊ីទៅមកៗចេញចូល ។

ប៊ុនថន ៖ ពូជូនទៅមកវិញ ខ្មែរក្រហមអត់ថាអីដែរ?

វុធឌី៖ កាលនោះខ្មែរក្រហមមិនទាន់មកដល់ភូមិនេះទេ ហើយគាត់រត់ អត់ទាន់ចូលមកដល់ទាន់តាមជាយដែន វាមិនទាន់ចូលមករៀបចំបានអស់ ដល់សម័យ៧៥ ពាក់កណ្តាល៧៥នេះ គេចាប់ផ្តើមឲ្យប្រជាពលរដ្ឋចាស់ៗនេះ បិទឫស្សីធ្វើចំរូងដាក់ខ្លួនឯងហើយ ធ្វើរបង គេធ្វើផ្លូវចំរាស់គេដើរ គេជីកអន្ទង់ មានជំរៅមួយម៉ែត្រជាងក៏មាន ជំរៅ១ម៉ែត្រទំហំ១ម៉ែត្រ ហើយគេដាក់ស្នឹកឈើ គេដោតចំរូងរួចបានគេដាក់ស្នឹកឈើ ។

ប៊ុនថន ៖ ធ្វើចំរូងហ្នឹង?

វុធឌី៖ បាទ! ចំរូងមានអាខ្លី ៨តឹកជាងក៏មាន ១ម៉ែត្រក៏មាន ឲ្យចាស់ៗបិទគល់ឫស្សី ។

ប៊ុនថន ៖ អីចឹងក្បាលទន្សោងពូ ភូមិនេះមានអ្នកជម្លៀសមកថ្មីពីភ្នំពេញ ឬពីណា?

វុធឌី៖ ពីភ្នំពេញគ្មានទេ ពួកអ្នកមកថ្មីមកនៅត្រឹមថ្មពួក ហើយនិងបន្ទាយឆ្មារមានខ្លះ ។

ប៊ុនថន ៖ ទៅក្បាលទន្សោងហ្នឹង?

វុធឌី៖ ក្បាលទន្សោងមិនមានទៅនៅទេ ។

ប៊ុនថន ៖ ពូធ្វើនៅហ្នឹង ធ្វើបានប៉ុន្មានឆ្នាំ ប្រធានឈ្លប?

វុធឌី៖ ខ្ញុំធ្វើបានមិនដល់១ឆ្នាំទេ ពាក់កណ្តាលឆ្នាំហ្នឹងឯងដែលខ្ញុំរត់ ខ្ញុំរត់ខែកក្តិក ។

ប៊ុនថន ៖ រត់ខែកក្តិក?

វុធឌី៖ បាទ! ខ្ញុំធ្វើនេះ ធ្វើដើម្បីរកផ្លូវចេញទេ ចង់ដឹងថាគេដាក់មីនត្រង់ណា អីត្រង់ណា ខ្ញុំរកកន្លែងចេញពីភូមិ ហើយខ្ញុំដើរប្រាប់ពួកអ្នកស្រុក អ្នកណាចង់រត់ចេញទៅនៅថៃ ដល់នេះថាទៅគ្នាច្រើន ដល់ខ្ញុំចាប់ផ្តើមគេថាគ្រោងការថានឹងចេញ ខ្ញុំឲ្យចាប់យកកាំភ្លើងឈ្លបកាំភ្លើងទាហាន គេហៅយោធាគេហ្នឹង ខ្ញុំនាំឈ្លប៣០នាក់ ទៅចាប់យកកាំភ្លើង៣០ តែចាប់បានតែ២-៣ដើម ដល់នេះពួកគ្នាយើងរត់មកមិនមានអ្នកណាតស៊ូជាមួយ រត់អស់រលីង ហើយពួកវាចាប់បានកាំភ្លើង៣ឡើង ខ្ញុំនាំពួកនេះឯងយកកាំភ្លើងសម្លាប់ពួកវារួចដល់ល្ងាចឡើងគេបញ្ជូនយោធាទៅចាប់ខ្ញុំ ខ្ញុំដឹងផែនការមុនហើយគេទៅសួរ សួរចំខ្ញុំហ្នឹងឯងគេថាប្រធានឈ្លបនៅទេ ខ្ញុំថាមិននៅទេ គាត់ដឹកស្បៀងទៅឲ្យចល័ត ហើយចល័តនៅអាងជើងគ្រួស ដែលបិទទំនប់អាងជើងគ្រួស ហើយខ្ញុំក៏នាំគេយាមគេ ថាបើចង់ឈ្លបចាប់យាម កំលាំងយាមក៏ខ្ញុំថា ពួកឈ្លបស្គាល់ផ្លូវច្បាស់ ថាខ្មាំងត្រូវរត់ខាងណាអីខាងណា ហើយខ្ញុំសុំ គេដាក់ខាងលិច ខាងត្បូង ខាងជើងឲ្យយោធាគេយាមត្រឹមខាងជើងមកខាងកើតទៅកៀនខាងត្បូង បើជួបគ្នាថាត្រូវធ្វើម៉េច ហ្នឹងបានដឹងថាគ្នាឯងគ្នាគេ ហើយខ្ញុំក៏

សួរគេថា បើយើងស្រែកថាដៃ ថាព្រាប បើអ្នកណាថាព្រាប ហើយយើងឆ្លើយថាដៃទៅ គេថាគ្នាឯង ម៉្លោះហើយខ្ញុំក៏នាំពួកឈ្លប ថានាំអ្នកនេះថាទេ អ្នកនោះថាទេ មិនហ៊ានទេ ដល់សម័យ នោះថាវាសាបព្រោះខ្លាំងណាស់ ឡើងមនុស្សខ្លាចមិនហ៊ាន តែប្រពន្ធកូនមិនហ៊ានប្រាប់ម៉្លោះហើយខ្ញុំថាមិនកើតទេ នៅច្បាស់ជាស្លាប់ ខ្ញុំក៏នាំគ្នា៣នាក់រត់ យកទាំងកាំភ្លើងទៅ ក៏ប៉ះពួកវានៅផ្លូវជម្ងៀសគេដាក់ គេធ្វើខ្ទមយាម មិនឆ្ងាយគ្នាទេ គេយាមផ្លូវខ្លាចមនុស្សរត់ចេញចូល ទៅក៏ឡើងរបងគេដាក់ របងនោះមានតែបន្លា របងដែលគេធ្វើ ។

ប៊ុនថន : បន្លាអីវិញ បន្លាបុស្សី ឬបន្លាលួស?

វុធឌី: អត់ទេ បន្លាយើង បន្លាអង្រ្កង បន្លាសធម៌មើលតែក្រាស់ ទំហំវា៣ម៉ែត្រ ទំហំរបង ខ្ញុំទៅដល់វាបាញ់ បាញ់បេមកចំខ្ញុំ ខ្ញុំចោលគ្រាប់បែក កាលនោះបានកាំភ្លើងទៅ៣ដើម បានស្ទែងទៅ១ដើម គ្រាប់ច្រើនហើយ ខ្ញុំបាញ់តឲ្យពួកនោះយកឈើយកដាក់គងឡើងចុះទៅខាងនោះ ហើយខ្ញុំក៏ដើរមុនគេ ដើរអន្ទុយរំកិលធាក់ចំរូង ធាក់ខ្លាចប៉ះអន្ទង់ជ្រៅ អន្ទង់រាក់ឲ្យគេច វាបែរបាញ់តនឹងពួកខ្មែរក្រហម ហើយខ្ញុំចេះតែនាំដើរ កាលនោះចំរូងក៏មុតច្រើន មុតតាមជើង ដល់ពួកថៃ ទៅដល់មានពួកខាងខ្មែរយើងដែររត់ទៅមុន ឈ្មោះ តាឡូត គាត់ទៅបង្កើតជាពួករំដោះ ពួកប៉ារ៉ា បង្កើតនៅ តាឡូត ខូចហើយសព្វថ្ងៃ គេបាញ់ហើយគាត់ទៅនៅ គ្នាក៏មិនច្រើនកាលនោះ គ្នាមួយក្រុម១២នាក់ យូរទៅបានច្រើនបានកើតពាន់ បានកើតសែន មិនតិចសែននាក់ទេ ដល់មកនៅសាយធូរ ខ្ញុំក៏បានចាប់ធ្វើប៉ារ៉ាតាំងពីនោះមក រហូតមក៨-១០ឆ្នាំដាង ។

ប៊ុនថន : ដំបូងខាងថៃអត់នេះដែរចូលទៅ? យើងមានអាវុធអីចឹង?

វុធឌី: ខ្ញុំកាលនោះយកទៅលាក់ ឆ្លងទៅ ខ្ញុំខ្លាចខ្លួនដែរ លាក់អាវុធរួចអីរួច ទៅដល់អ្នកស្រុកគេរត់ អ្នកប្រូតគេរត់ ទៅដល់ខ្ញុំនាំគ្នាមានបាយ នាំគ្នាហូបបាយ បាយពួកអ្នកដែលគេរត់ គេអ្នកប្រូត គេរត់ទៅប្រាប់ស្រុកគេ មានពួកគេហៅពួកឈុតខ្មៅ ពួកស្រុកគេហៅឈ្លបស្រុកគេ ដល់ហើយមានស្គាល់គ្នីគ្នាខ្ញុំ ក៏ទៅក្រាបឆ្ងាយពីខ្ទមហូបបាយ រួចនាំគ្នាក្រាបមើលឲ្យគេដើរមកដុត ដើរហួសទៅអីចេះបានហៅគេ ឲ្យគេបែរ កាលនោះតែលឺសួរគេក៏ប្រយ័ត្នប្រយ័ត្នតាមព្រំប្រទល់ គេមកត្រៀមមានមនុស្សមកគេចាំទទួល កាលសម័យនោះដល់នេះទៅខ្ញុំទៅក៏ស្គាល់គ្នា ពួកអាចិនហេ ពួកអាចិនរ៉ាត់ អាពួកចិនវៀ ស្គាល់គ្នាច្រើនខាងថៃ ដែលគ្នាដើរលេងពីដើមម៉ិញកំលោះ ។

ប៊ុនថន : ខាងទាហានថៃហ្នឹង?

វុធឌី:	បាទ! គេប្រាប់ថាដាហើយ គេមានពួកខ្មែរស កាលសម័យនោះគេហៅខ្មែរសមក គេបង្កើតខ្ញុំថាខ្មែរស ខ្ញុំថាអីណាចេះ ថាពួកខ្មែរយើង ដែលរត់មកនៅតាំងជំរុំនៅនោះមានតែប្រុសៗទេ មិនមានស្រីទេកាលសម័យនោះ កាំភ្លើងគេទិញកាំភ្លើងខ្លះ កាំភ្លើងលោកសង្ឃខ្លះ ដែលខ្ញុំបានទៅពីនេះខ្លះ ដល់នេះនៅនឹងគេនោះ គេឲ្យចុះមកយកការណ៍នៅស្រុកខ្មែរយើង ថាអ្នកណាហ៊ានចុះទៅ ក៏រៀបចំ កាលសម័យនោះយើងស្លៀកពាក់ឲ្យដូចយោធាគេនៅនេះ បើទ័ពស្រុកស្លៀកពាក់ខោអាវឈុតគគីរ ស្បែកជើង មួកដូចគេចេះប្រឡាំតែមិនហ៊ានចូលក្នុងភូមិខ្លួនយើងទេ ខ្លាចគេស្គាល់ ចូលទៅភូមិឆ្ងាយៗដែលគេមិនស្គាល់ កាលសម័យនោះតែឃើញយោធាខ្លាចណាស់ សម័យប៉ុលពត ឃើញចូលមក ដូចជាបាយទឹកមិនខ្វះទេ មិនមែនដូចសម័យយួនទេ សម័យប៉ុលពតនេះចូលមកយកអង្ករយកស្បៀងគេហៅសហករណ៍នោះ គឺឃ្លាំងតាមភូមិ មកសុំគេ កាលនោះគេមិនហៅសុំទេ គេនិយាយស្មើរ ត្រីងៀន សុំចប់ រឿងហូប អង្ករ ស្បៀង គេឲ្យអត់បាច់ទិញដូរទេ សម័យប៉ុលពត ដល់មកសម័យយួនចូលភូមិ លំបាកណាស់ ខ្មែរក្រហមវាមិនសូវត្រង់ត្រាប់ដូចយួនទេ ធូររលុងជាងយួន។

ប៊ុនថន :	ពូចូលមកលួចលាក់ទេ អត់ឲ្យគេដឹង ឬយ៉ាងម៉េច?

វុធឌី:	ចូលមកបន្លំគេហៅថាយកការណ៍ តែមិនចូលតាមភូមិដែលគេស្គាល់យើងច្រើន ខ្លាចគេហៅទៅបែកការណ៍ អត់ចូលបានទេ បើដើរកាត់មកវិញមានអីក្បែរៗភូមិ ពីដើមមិញតែឲ្យគេ ដឹងគេយកបងប្អូន កូនចៅ ម៉ែឪ យកទៅវ៉ៃសម្លាប់ចោល។

ប៊ុនថន :	អីចឹងគ្រួសារលោកពូគេនៅនេះទេ?

វុធឌី:	គេជម្លៀសទៅនៅដើរទទាល ទាំងឪពុកម្តាយខ្ញុំជម្លៀសទៅឆ្ងាយ ទៅខាងត្បូងថ្មពួកគេហៅដើរទទាល ជម្លៀសចេញពីភូមិ។

ប៊ុនថន :	ពូទៅនោះម្នាក់ឯងទេ?

វុធឌី:	ទៅនោះម្នាក់ឯង។

ប៊ុនថន :	ពេលវៀតណាមចូលមកពូនៅទឹកដីថៃ ឬមកចូលក្នុងភូមិវិញ?

វុធឌី:	ខ្ញុំនៅនោះឯង នៅសាយធូរ នៅវ៉ៃជាមួយខ្មែរក្រហម វ៉ៃជាមួយយួន កាលនោះតាំងជំរុំនៅបឹងអំពិល ដល់បែកបឹងអំពិលទៅសាយវ៉ាន់ ចេញពីសាយវ៉ាន់ បានទៅសាយធូរ។

ប៊ុនថន :	កាលហ្នឹងពូនៅជាមួយណា? ខាង សៀនសាន?

វុធឌី:	ខាង តាសឿន សាន មិនមែននៅខាងសម្តេចទេ គឺនៅខាង តាសឿន សាន។

ប៊ុនថន ៖ ពូដែលចុះឡើងមកវៃ មកដល់ណាខ្លះ?

វុធឌី៖ មកនេះឯង ទៅដល់កំពង់ធំក៏ទៅ ឆ្លងទន្លេសាបទៅកំពង់ចាមក៏ទៅ ១៥ថ្ងៃ ១៥យប់នោះ ខ្ញុំមិនសូវបានឡើងទៅទេ មកនៅខ្មែរក្រោម ។

ប៊ុនថន ៖ នៅបន្ទាយឆ្មារ នៅថ្មពួក ពូដែលមកទេ?

វុធឌី៖ មកតែ មកនៅតាមព្រៃ នៅមួយជួរអណ្តូងបរ ចូលមកយកការណ៍នៅតាមភូមិថ្មី ថ្មពួក ដែលវៃនឹងបន្ទាយឆ្មារនេះ វៃច្រើនដងហើយ២-៣ដង ។

ប៊ុនថន ៖ វៃយកបានទេបន្ទាយឆ្មារពូ?

វុធឌី៖ វៃបែកមុនដំបូង លើកក្រោយវៃយករថក្រោះ បានរថក្រោះ១នៅជា អា១នេះ បាន២ អាមួយវាខូចដាច់ច្រវ៉ាក់ ។

ប៊ុនថន ៖ វៃជាមួយវៀតណាម?

វុធឌី៖ បាទ! ជាមួយវៀតណាម ។

ប៊ុនថន ៖ ប្រជាជននៅហ្នឹងម៉េចដែរពូ? នៅមានខ្មែរក្រហមអីហ្នឹងទេ?

វុធឌី៖ ទេ មិនមានខ្មែរក្រហមទេ កាលសម័យយួនចូលមកតាមនេះហើយ ខ្មែរក្រហមនៅខាង តាម៉ុក នៅខាងអន្លង់វែងនោះ នៅខាងដីថៃ ដូចគ្នាហ្នឹងឯងមិនសូវមាននៅហ្នឹងទេ នៅក្នុង តែទ័ពចល័ត ។

ប៊ុនថន ៖ ប្រាសាទបន្ទាយឆ្មារគ្រាន់កងទ័ពប៉ារ៉ា ឈរជើងនៅហ្នឹង ឬយ៉ាងម៉េច?

វុធឌី៖ ទេ មិនមែនឈរជើងនៅទេ មានតែយួនទេនៅ ដល់បែក យួនត្រឡប់ទៅស្រុកបានចូល មកនៅ ។

ប៊ុនថន ៖ ចូលមកប៉ារ៉ាបោះទីតាំងនៅហ្នឹងតែម្តង?

វុធឌី៖ បាទ!

ប៊ុនថន ៖ ខ្មែរក្រហមអត់ដែលឈ្លបចូលវៃនៅនេះទេពូ?

វុធឌី៖ មិនដែលចូលវៃទេ វៃចុងក្រោយដែលត្រូវគ្នាហើយ អានោះខ្មែរក្រហមមកវៃនេះម្តង ។

ប៊ុនថន ៖ វៃប៉ារ៉ា?

វុធឌី៖ បាទ! វៃប៉ារ៉ា កាលនោះវៃប្លន់ វៃលួចទ្រព្យសម្បត្តិ យកនឹងផ្សារ ។

ប៊ុនថន ៖ ពូនៅប៉ារ៉ារហូតដល់ឆ្នាំណា.....?

វុធឌី៖ ៩៤ខ្ញុំឈប់ ។

ប៊ុនថន ៖ ៩៤បានឈប់?

វុធឌីៈ បាទ!

ប៊ុនថន : ពូដូចប្រាសាទនេះមានបាត់ ខាងណាវិញកាលហ្នឹង?

វុធឌីៈ ប្រាសាទនេះដល់វាច្រើនសម័យ ច្រើនជំនាន់អីចេះ វាបាត់ពីមុនដំបូង ពីខ្ញុំនៅបួស កាលនោះវត្ថុបុរាណនៅល្អណាស់ នៅច្រើនៗ

ប៊ុនថន : ពេលណានៅបួសហ្នឹង ឆ្នាំណាពូនៅបួស?

វុធឌីៈ នឹកមិនឃើញទេ មិនដឹងឆ្នាំណា កាលខ្ញុំបួស កាលនោះមានឆ្មាំប្រាសាទ កូនមេឃុំ កូនតាណៅ អាណាតនោះគេឆ្មាំប្រាសាទ អ្នកយកបុរាណទុកនៅហ្នឹងឃ្លាំង ដល់យូរៗទៅ យកទៅលក់ តាណងហ៊ាន អាចារ្យស្គន់ នេះគេដាក់ដំរីយកទៅលក់នៅថៃៗ

ប៊ុនថន : កាលហ្នឹងនៅសម័យ លន់ នល់?

វុធឌីៈ បាទ! មុន លន់ នល់ ដាក់ដំរីទៅលក់ឯថៃ លក់ឲ្យកូនគ្រូប៊ុនសុំ ដល់ទៅមកមើលខ្ញុំភ្លេចឈ្មោះ ប៊ូ ទន គាត់មកឈរជើងនៅថ្មពួកនេះ ដល់នេះគាត់មិនឲ្យធ្វើទេ គាត់ចាក់ គាត់ប្រមូលយកទៅដាក់ ឃ្លាំងខាងក្នុងយកទៅរក្សាទុក តែអ្នកណារកគេចាប់សម្លាប់ចោល បាញ់ចោលហើយគាត់មិនដែលទុកៗ ដល់នេះ អាណាត ខ្លាចខ្លួន ខ្លាចបែកការណ៍ វាក៏សរសេរសំបុត្រដាក់ក្នុងរទេះ វាបាញ់ខ្លួនវាសម្លាប់មិនឲ្យបែកការណ៍ដល់បងប្អូន ដល់ម៉ែឪទេៗ

ប៊ុនថន : សរសេរសំបុត្រម៉េចវិញ?

វុធឌីៈ សរសេរសំបុត្រទុកៗ

ប៊ុនថន : ដាក់ថាម៉េចវិញ?

វុធឌីៈ អានោះខ្ញុំមិនបានមើលទេ ឃើញតែអ្នកគេមើល អានោះខ្ញុំមកបួស ខ្ញុំដឹងតែវាបាញ់ខ្លួនវាសម្លាប់ខ្លួន ពីព្រោះវាឆ្មាំប្រាសាទនោះវាត្រូវតែដឹង អ្នកឲ្យលក់ៗ

ប៊ុនថន : ក្រោយមកប៉ុល ពតមានបាត់?

វុធឌីៈ ដល់មកសម័យប៉ុល ពត គាស់ច្រើនអស់លោកគេអ្នកយក មុនដំបូង អាលក្ខិណា មកនៅនេះ អាលក្ខិណាក៏យកទៅមួយសារៗ

ប៊ុនថន : លក្ខិណា ហ្នឹងគាត់ធ្វើអីវិញ?

វុធឌីៈ ប៉ុល ពតហ្នឹងឯង ដល់គេមកនៅឈរជើងនៅនេះ គេខាងស្រុក ក្រោយមកទៀត អា ស៊ិន សុផាត គេក៏នៅ ដល់មកមាន អាហ៊ិត ហៅ ខាវ ហ៊ិត នាំទាហានគាស់អាហ្នឹងខ្ញុំឈប់ហើយ គាស់បានយកទៅលក់ អ៊ូ! អរណាស់ៗ

ប៊ុនថន ៖	លក់ឲ្យថៃអីពូ?

វុធឌី៖	គេលក់ទៅតែថៃនោះ ខ្ញុំមិនដែលដឹងរឿងគេទេ ម្ដាយឪពុកខ្ញុំផ្ដាំដេរមិនឲ្យយកដើងទៅជាន់ថ្មទៀត គាត់មិនឲ្យប៉ះពាល់ទេ ។

ប៊ុនថន ៖	គាស់អស់ច្រើនទេពូ ស្អីខ្លះដែលយកទៅ?

វុធឌី៖	ខ្ញុំមិនដឹងផងទេ លឺតែគេថាបាន អ្នកបានគេបានច្រើន ហើយគេជីកទាំងឡានៗ មិនដឹងជាជីកស្អី ខ្ញុំមិនដែលបៀតបតទេ ខ្ញុំមិនដែលប៉ះពាល់ទេអារឿងអីចឹង ធម្មតាមាមេទាហានមានតែខ្ញុំទេក្រដាងគេ មួយវរសេនាធំ តែកង់មិនដែលមានជិះ បានខ្ញុំឈប់ដោយសារខ្ញុំស្មោះ ខ្ញុំស្រណោះទាហាន ស្រណោះអ្នកដើរតាម មិនដែលលួច នាំគេរកស៊ីអាដ្ឋវខុសស្រណោះអ្នកមាន មើលគ្នាពិការហើយមិនមានបៀវត្សអីស៊ី ថែមទាំងខ្ញុំ ឈ្មោះខ្ញុំក៏នៅសព្វថ្ងៃដែរខ្ញុំមិនដែលទាមទារ កាលខ្ញុំឈប់ ខ្ញុំភ្លាយមួយខ្ញុំឈប់ ។

ប៊ុនថន ៖	ពូបានផ្កាយមួយដែរ?

វុធឌី៖	បាទ!

ប៊ុនថន ៖	ផ្កាយមួយខាងណាវិញ?

វុធឌី៖	ខាង ស៊ឹន សាន ខ្ញុំឈប់ សួរតែ ញឹក ប៊ុនឆៃ ក៏រៀនជាមួយខ្ញុំ ទៅរៀនកងពលតូចជាមួយ ។

ប៊ុនថន ៖	ពូនៅជាមួយគ្នា ញឹក ប៊ុនឆៃ?

វុធឌី៖	ទេ ទៅរៀនមួយសេបភីគេយក១០ សម្ដេច១០ ខាងខ្ញុំនេះ១០ ខាងតា ស៊ឹន សានយកមួយដំរុំម្នាក់ យកទៅឲ្យរៀន រៀនកបាល់ញា រៀនកងពល រៀនច្រើនណាស់ រៀនខាងនយោបាយ ។

ប៊ុនថន ៖	នៅស្គាល់ទេ ញឹក ប៊ុនឆៃ ឥលូវ?

វុធឌី៖	វាហៅហ្នឹងឯង កាលមករអែងហៅខ្ញុំ តែខ្ញុំមិនដែលទៅ ខ្ជិលបៀតបត ។

ប៊ុនថន ៖	ចុះសម្ដេចក្រុមព្រះអី ពេលនេះហើយចូលជាមួយគ្នា លោកពូនៅជាមួយគ្នា?

វុធឌី៖	ចូល នៅជាមួយ គាត់មកតាម២-៣ដងដែរ ខ្ញុំមិនដែលទៅ ខ្ញុំឈប់ហើយ ខ្ជិលរវីរវល់សុខចិត្តឃ្វាលគោមេល្អជាង ធ្វើស្រែស្រួលចិត្ត ។

ប៊ុនថន ៖	ចុះរាល់ថ្ងៃពូធ្វើអីវិញ?

វុធឌី៖	ខ្ញុំធ្វើស្រែ ដើរឃ្វាលតែគោមេ ។

ប៊ុនថន ៖	ប៉ុន្មានក្បាលពូ?

វុធឌី:	ប្រហែលសាមសិបដាង តែខ្ញុំលក់ម៉ត់ កាលពីដើមមិញកាលសម័យខ្ញុំធ្វើប៉ារ៉ាខ្ញុំទិញឲ្យតាមភូមិគេចិញ្ចឹមទុកឲ្យ ចិញ្ចឹមប្រវ៉ាស់ មួយភូមិមួយនឹម ទៅប្រចាំការនោះឲ្យ ១-២នឹម អ្នកដែលអត់ ដល់ខ្ញុំឈប់សម័យ៩៨នេះខ្ញុំទៅប្រមូលមកចែកគ្នា ខ្ញុំបានគោមួយរយដាងក្បាល បានគោនោះហើយគម ខ្ញុំមិនដែលផឹក មិនដែលស៊ី មិនដែលលេងសើចនឹងគេ ។

ប៊ុនថន :	កូនប៉ុន្មាននាក់?

វុធឌី:	ខ្ញុំកូន៨នាក់ ។

ប៊ុនថន :	ប៉ុន្តែមានគ្រួសារអស់ខ្លះហើយ?

វុធឌី:	មានគ្រួសារ៧នាក់ហើយ នៅម្នាក់ដែលធ្វើដាងឡានទៅអាមេរិក នៅមិនទាន់បានគ្រួសារទេ ។

ប៊ុនថន :	អីចឹងខ្ញុំដូចអស់អីសួរពូហើយ អរគុណពូច្រើន ។

វុធឌី:	បាទ! សុខសប្បាយ ។

**ចប់**